Energy & Water Ombudsman NSW
Free, fair and independent

# តើអ្នកមានបញ្ហានានាជាមួយនឹងក្រុមហ៊ុនអគ្គិសនី, ឧស្ម័ន ឬទឹកទេ?

ស្ថាប័ន **EWON** ជួយដល់បណ្តាជននៅក្នុងរដ្ឋ **New South Wales** ដែលកំពុងជួបប្រទេះនឹងបញ្ហាផ្សេងៗជាមួយនឹងក្រុមហ៊ុនថាមពលរបស់ពួកគេ ។ យើងខ្ញុំក៏អាចជួយដល់បណ្តាអតិថិជនទឹកខ្លះផងដែរ ។

យើងខ្ញុំ **មិនគិតថ្លៃ**

យើងខ្ញុំ **យុត្តិធម៌**

យើងខ្ញុំ **ឯករាជ្យ**

## តើអ្នក៖

- មានបញ្ហានៅក្នុងការយល់វិក្កយបត្រទឹក ឬថាមពលរបស់អ្នកទេ?
- មានការលំបាកនៅក្នុងការបង់វិក្កយបត្ររបស់អ្នកទេ?
- មានបញ្ហាជំពាក់បំណុល ឬការលំបាកក្នុងការបង់សងប្រាក់ទេ?
- មានការខ្វាយខ្វល់បារម្ភអំពីបញ្ហាគេផ្តាច់សេវាកម្មទេ?
- មិនសប្បាយចិត្តនឹងសេវាកម្មអតិថិជនរបស់ក្រុមហ៊ុនអ្នកទេ?
- មានបញ្ហាបើក ឬបិទគណនីទេ?
- មានបញ្ហានៅក្នុងការទទួលបានតម្លៃល្អសម្រាប់ប្រាក់ចំណាយទេ?

## របៀបដែលយើងអាចជួយបាន

- យើងស្តាប់អ្នក និងជួយអ្នកសម្រេចចិត្តនូវអ្វីដែលត្រូវធ្វើ
- ប្រសិនបើអ្នកត្រូវការអ្នកបកប្រែភាសា យើងអាចហៅឲ្យបាន
- យើងអាចរៀបចំឲ្យមានបុគ្គលិកជាន់ខ្ពស់ពីក្រុមហ៊ុនរបស់អ្នកទាក់ទងទៅអ្នក
- យើងអាចជួយចរចារកដំណោះស្រាយលទ្ធផល
- យើងអាចស៊ើបអង្កេតនូវបណ្តឹងរបស់អ្នក
- យើងអាចបញ្ជូនអ្នកទៅឲ្យបណ្តាទីភ្នាក់ងារដទៃទៀត ប្រសិនបើយើងមិនអាចជួយបាន

## ជំនួយផ្នែកវិក្កយបត្រ

- ទាក់ទងទៅក្រុមហ៊ុនរបស់អ្នកជាមុនសិន ប្រសិនបើអ្នកមិនអាចបង់ប្រាក់បានទាន់ពេលវេលាទេនោះ ដើម្បីបញ្ឈប់កុំឲ្យបំណុលរបស់អ្នកកាន់តែកើនឡើងច្រើន
- យើងអាចព្យាយាមជួយសុំពេលបន្ថែមដល់អ្នកដើម្បីបង់ប្រាក់វិក្កយបត្ររបស់អ្នក
- យើងអាចជួយអ្នកចរចារកផែនការបង់សងប្រាក់ ដើម្បីឲ្យអ្នកអាចបង់សងប្រាក់លើវិក្កយបត្ររបស់អ្នករហូតដល់សងរួច
- យើងអាចជួយអ្នកឲ្យទទួលបាននូវកម្មវិធីផ្សេងៗដែលធូរថ្លៃ
- យើងអាចផ្តល់ឱវាទផ្សេងៗដល់អ្នកនូវរបៀបសន្សំប្រាក់លើវិក្កយបត្រ
- យើងអាចផ្តល់ព័ត៌មានដល់អ្នកអំពីជំនួយហិរញ្ញវត្ថុដែលមានជូន

## គន្លឹះផ្សេងៗសម្រាប់ការដោះស្រាយបណ្តឹងនានា

- ប្រសិនបើអ្នកមានបញ្ហាជាមួយនឹងក្រុមហ៊ុនរបស់អ្នក សូមទាក់ទងទៅពួកគេ ហើយពន្យល់អំពីស្ថានភាពរបស់អ្នក
- អ្នកអាចស្នើឲ្យមិត្តភក្តិ ឬសមាជិកក្រុមគ្រួសារជួយនិយាយជាមួយគេជំនួសឲ្យអ្នក
- ប្រសិនបើអ្នកត្រូវការអ្នកបកប្រែភាសា សូមប្រាប់ទៅក្រុមហ៊ុនរបស់អ្នក
- រក្សាទុកនូវលិខិត, ឈ្មោះជនដែលអ្នកបាននិយាយជាមួយ និងពេលវេលាថ្ងៃខែដែលបានទាក់ទង
- ប្រសិនបើបុគ្គលិកនៅកន្លែងទទួលទូរសព្ទមិនអាចជួយអ្នកបាន សូមស្នើសុំនិយាយជាមួយនឹងបុគ្គលិកជាន់ខ្ពស់ណាម្នាក់
- ប្រសិនបើបញ្ហានៅតែមិនអាចដោះស្រាយបាន សូមទាក់ទងមកយើងខ្ញុំ

## របៀបទាក់ទងយើងខ្ញុំ

**អ្នកអាចនិយាយជាមួយយើងខ្ញុំដោយប្រើអ្នកបកប្រែភាសា។**

សូមទូរសព្ទទៅសេវាកម្មបកប្រែភាសា **(Translating and Interpreting Service)** តាមលេខ **131 450** ហើយស្នើសុំជួបពួកយើង

អ្នកអាចស្នើសុំឲ្យមិត្តភក្តិ, សមាជិកគ្រួសារ ឬបុគ្គលិកសហគមន៍ឲ្យជួយនិយាយជាមួយយើងខ្ញុំជំនួសលោកអ្នក

**ទូរសព្ទឥតគិតថ្លៃមកយើងខ្ញុំតាមលេខ 1800 246 545**

(ប្រសិនបើអ្នកហៅចេញពីទូរសព្ទចល័ត, សូមប្រាប់យើងឲ្យដឹង ហើយយើងនឹងទូរសព្ទទៅអ្នកវិញ)

ចំពោះព័ត៌មានបន្ថែម ឬក៏ដាក់ពាក្យបណ្តឹងតាមអ៊ីនធើរណិត សូមបើកមើលវិបសាយថ៍របស់យើង

**www.ewon.com.au**